ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ : ....668 .PEAC.អក

រាជធានីភ្នំពេញ, ថ្ងៃទី 18 ខែ ឧសភា ឆ្នាំ 2016

# សេចក្តីជូនដំណឹងលើកទី ២

ស្តីពី

**ការចាក់បេតុងដែកផ្លូវនិងទីធ្លាទំហំ 5,165.40 m² រៀបប្រព័ន្ធលូបង្ហូរទឹក ប្រវែង 636 m នៅទីតាំងដីវត្តស្លែង**

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា អគ្គិសនីកម្ពុជានឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការចាក់បេតុងដែកផ្លូវនិងទីធ្លាទំហំ 5,165.40 m² រៀបប្រព័ន្ធលូបង្ហូរទឹកប្រវែង 636 m នៅទីតាំងដីវត្តស្លែង ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ។ ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋានៈ អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី 19 ខែ ឧសភា ឆ្នាំ 2016 តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ៖ 023 67 66 007 និង Website : www.edc.com.kh ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹមថ្ងៃទី 02 ខែ មិថុនា ឆ្នាំ 2016 វេលាម៉ោង 14:00 ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង 16:30 ថ្ងៃទី 02 ខែ មិថុនា ឆ្នាំ 2016 ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ

ELECTRICITE DU CAMBODGE